**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះរាជហស្ថលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ១៩៩៥*

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

* * *

# II- ទីស្តីការគណៈរដ្ឋមន្ត្រី

## ១. អនុក្រឹត្យ

*រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ១៩៩៥*

### អនុក្រឹត្យលេខ ៣៥ អនក្រ
### ស្តីពីការបង្កើតគណៈកម្មាធិការ
### ជាតិគ្រប់គ្រងគ្រោះមហន្តរាយ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងគ្រប់គ្រងរើដ្ឋាន

**សំរេច**

**មាត្រា ១ :** បង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដែលមានសមាសភាពដូចខាងក្រោម ÷

១-សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ និង សម្តេចនាយករដ្ឋមន្ត្រីទី ២ ជាសហប្រធាន

២_សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ អនុប្រធាន

៣_សហរដ្ឋមន្ត្រី ទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៤_សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ ជាសមាជិក

៥_រដ្ឋមន្ត្រី ក្រសួងគ្រប់គ្រងបរិស្ថាន ជាសមាជិក

៦_រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសមាជិក

៧_រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន ជាសមាជិក

៨_រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាសមាជិក

៩_រដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

១០_រដ្ឋមន្ត្រីក្រសួងសុខាភិបាល ជាសមាជិក

១១_រដ្ឋមន្ត្រី ក្រសួងផែនការ ជាសមាជិក

១២_រដ្ឋមន្ត្រី ក្រសួងពត៌មាន ជាសមាជិក

១៣_រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានកិច្ចការនារី ជាសមាជិក

១៤_ប្រធាន កាកបាទក្រហមកម្ពុជា ជាសមាជិក

១៥_លោកអគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសមាជិក

**មាត្រា ២ :** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានតួនាទី និងភារកិច្ចដូចតទៅ ÷

១_រៀបចំគោលការណ៍ចាំបាច់ ទាក់ទងនិងការគ្រប់គ្រងគ្រោះមហន្តរាយ ។

២_ផ្តល់យោបល់ជូនគណៈរដ្ឋមន្ត្រី ស្តីពីការបង្ការគ្រោះមហន្តរាយ ត្រៀមលក្ខណៈទប់ទល់គ្រោះមហន្តរាយ ការប្រតិបត្តិការនៅពេលមានគ្រោះមហន្តរាយ ការជំរុញ ការស្តារស្ថានភាពឡើងវិញដោយរាជរដ្ឋាភិបាល កាកបាទក្រហមកម្ពុជា ព្រមទាំងការឧបត្ថម្ភពីភ្នាក់ងារអង្គការមិនមែនរដ្ឋាភិបាល និង អង្គការអន្តរជាតិនានា ។

៣_ណែនាំពីសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយ ដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត ក្រុង និងស្រុក ខ័ណ្ឌ ហើយនិងស្ថាប័នដទៃទៀត ។

៤_ធ្វើសំណើទៅរាជរដ្ឋាភិបាល ស្តីអំពីសេចក្តីត្រូវការ និងការប្រើប្រាស់ធនធានដូចជា មូលនិធិ សំភារៈ មធ្យោបាយ ប្រេងឥន្ធនៈ និង សំភារៈចាំបាច់ដទៃទៀតសំរាប់បំរើដល់ការខូចខាតដោយគ្រោះមហន្តរាយ ។

៥_អំពាវនាវដល់ស្ថាប័នជាតិ ភ្នាក់ងារអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងនិងក្រៅប្រទេស និងសប្បុរសជនទាំងឡាយដទៃទៀត ដើម្បីចូលរួមសហការជាមួយគណៈកម្មាធិការនេះ ។

៦_អំពាវនាវដល់ស្ថាប័នជាតិដទៃទៀត ដើម្បីជួយផ្តល់អ្នកជំនួយការក្នុងសកម្មភាពនេះ ។

**មាត្រា ៣ :** សមាជិកនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវចូលរួមប្រជុំអោយបានទៀងទាត់តាមការកោះអញ្ជើញរបស់ប្រធាន ។

**មាត្រា ៤ :** រចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានបញ្ជាក់ច្បាស់ដូចមានក្នុងឧបសម្ព័ន្ធ ១ ។

**មាត្រា ៥ :** តួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ :

ក_លេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ ដឹកនាំដោយលេខាអចិន្ត្រៃយ៍មួយរូប ដែលកំណត់ដោយប្រធានគណៈ កម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

ខ_លេខាធិការដ្ឋាននេះ ជាស្ថាប័នដោយឡែកចំណុះអោយទីស្តីការគណៈរដ្ឋមន្ត្រីដែលមានមន្ត្រី មកពីក្រសួងពាក់ព័ន្ធចូលរួមអនុវត្តការងារ ។

គ_លេខាធិការដ្ឋាននេះ ត្រូវអនុវត្តការងាររបស់ខ្លួនតាមការដឹកនាំរបស់គណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយ ហើយមានតួនាទី និងភារកិច្ចដូចខាងក្រោម :

១_រៀបចំកម្មវិធីសំរបសំរួលការងារជាមួយស្ថាប័ននានា ដើម្បីបំណុះបណ្តាលជំនាញដល់សមាជិកគណៈកម្មាធិការ ជាតិគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត ក្រុង ស្រុក ខ័ណ្ឌ និង អប់រំផ្សព្វផ្សាយដល់សាធារណជន ។

២_ប្រមូលទិន្នន័យគ្រោះមហន្តរាយ ដើម្បីធ្វើជាមូលដ្ឋានក្នុងការវាយតំលៃប៉ាន់ស្មានអំពីការខូចខាត និងរៀបចំកម្មវិធីស្តារ និងកសាងឡើងវិញ នូវហេដ្ឋារចនាសម្ព័ន្ធដែលខូចខាត ដោយសំរបសំរួលការងារជាមួយស្ថាប័ននានា អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ ។

៣_រៀបចំកម្មវិធីសិក្សាស្រាវជ្រាវនៅតាមតំបន់ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ ភ្លើងឆេះព្រៃ ជំងឺរាតត្បាត និងតំបន់ដែលរងគ្រោះដទៃទៀត ។

៤_រៀបចំផែនការជាយថាហេតុសំរាប់សង្គ្រោះជាបន្ទាន់ ដូចជា ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ អគ្គិភ័យ ភ្លើងឆេះព្រៃ ជំងឺរាតត្បាត និងគ្រោះមហន្តរាយដទៃទៀត ។

៥_ប្រកាសភាពអាសន្ន និងជូនពត៌មានដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត ក្រុង ស្រុក ខ័ណ្ឌ និងសាធារណជន អំពីគ្រោះមហន្តរាយដែលនឹងកើតមានឡើង ។

៦_ណែនាំទិសដៅ និងបច្ចេកទេស ដឹកនាំការងារដល់លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ថ្នាក់ខេត្ត ក្រុង និងស្រុក ខ័ណ្ឌ ។

៧_សំរបសំរួលជាមួយស្ថាប័ន និងអង្គការនានាដែលពាក់ព័ន្ធ ដើម្បីបង្កើតខ្សែសង្វាក់ទាក់ទងដល់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គ្រប់ខេត្ត ក្រុង និងស្រុក ខ័ណ្ឌ ។

៨_ទំនាក់ទំនងការងារជាមួយស្ថាប័ន អង្គការនានា កាកបាទក្រហម និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់ខេត្ត ក្រុង និងស្រុក ខ័ណ្ឌ ។

៩_សំរបសំរួលការងារជាមួយស្ថាប័ន អង្គការនានា ដើម្បីផ្តល់ជំនួយជួយជន្លៀស រកជំរកការពារសន្តិសុខ អប់រំសាធារណៈ និងរៀបចំកម្មវិធីផ្សេងៗទៀត ។

១០_ទទួលបន្ទុកកិច្ចការរដ្ឋបាលរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

១១_ជំរុញសកម្មភាពការងាររបស់មណ្ឌលសង្គ្រោះបន្ទាន់នៅពេលមានភាពអាសន្ន និងមុនពេលមានភាពអាសន្ន ។

១២_ធ្វើរបាយការណ៍ ថ្វាយ និងជូនដល់គណៈកម្មាធិការជាតិតាមតំរូវការ ។

ឃ_លេខាធិការដ្ឋាននេះមានផ្នែកទទួលខុសត្រូវភារងារដូចខាងក្រោមនេះ :

-ផ្នែកបណ្តុះបណ្តាល សិក្សាស្រាវជ្រាវ ទំនាក់ទំនងការងារ និងផ្តល់ពត៌មាន

-ផ្នែក គ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ សំរបសំរួល និងផ្គត់ផ្គង់កសុការ

-មជ្ឈមណ្ឌលសង្គ្រោះជាបន្ទាន់ និងការស្តារឡើងវិញ

**មាត្រា ៦ :** មជ្ឈមណ្ឌលប្រតិបត្តិការបន្ទាន់មាន ៣ក្រុមសំរាប់ទទួលខុសត្រូវការងារ នៅពេលមានគ្រោះមហន្តរាយ និងមានមុខងារដូចខាងក្រោម :

-ក្រុមសង្គ្រោះជន្លៀស និង ដឹកជញ្ជូនសំភារៈ

-ក្រុម ការពារសុខភាព ផ្តល់ជំនួយ និងរក្សាសុខមាលភាព

-ក្រុម ការពារសន្តិសុខ និងទំនាក់ទំនងការងារ

**១.ក្រុម សង្គ្រោះ ជន្លៀស និង ដឹកជញ្ជូនសំភារៈ :**

-ការងារជួយសង្គ្រោះ និងជន្លៀស : ត្រូវអនុវត្តការងារផ្នែកតាមស្ថានភាពនៃគ្រោះមហន្តរាយដែលកើតឡើង ហើយតម្រូវអោយមានការជួយសង្គ្រោះជាបន្ទាន់ បង្កើតមណ្ឌលត្រួតពិនិត្យត្រូវរៀបចំ ( ១ ) ក្រុមប្រតិបត្តិការជួយសង្គ្រោះ និង ( ២ ) ក្រុមផ្តល់របាយការណ៍ពីសេចក្តីត្រូវការនៃជំនួយសង្គ្រោះ ។ ចំនួននៃក្រុមជួយសង្គ្រោះអាស្រ័យទៅតាមតម្រូវការ និងប្រភេទនៃគ្រោះមហន្តរាយនៅតាមតំបន់ ។ ការជួយសង្គ្រោះត្រូវស្នើឡើងដោយគណៈកម្មាធិការថ្នាក់លើ ឬ អង្គការអន្តរជាតិនានា ។

-ការងារដឹកជញ្ជូន : ត្រូវគ្រប់គ្រងការដឹកនាំជញ្ជូន និងពិនិត្យលើលទ្ធភាពនៃការដឹកជញ្ជូនសំភារៈហើយធានាគុណភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់សំភារៈទាំងនេះនៅតាមតំបន់ដែលកើតគ្រោះមហន្តរាយ ។ រាល់សំណើទាំងឡាយ ដែលទាក់ទងទៅនឹងការដឹកជញ្ជូនសំភារៈត្រូវស្នើទៅក្រុមការងារដឹកជញ្ជូន ។ ក្រុមការងារដឹកជញ្ជូននេះក៏ទទួលខុសត្រូវក្នុងការដឹកជញ្ជូនសំភារៈពីតំបន់ជិតៗផងដែរ ។

**២.ក្រុមការពារសុខភាព ផ្តល់ជំនួយ និងរក្សាសុខមាលភាព :**

-ការងារការពារសុខភាព : រៀបចំបរិក្ខារសំរាប់ការពារសុខភាព បណ្តុះបណ្តាលបុគ្គលិកផ្នែកការពារសុខភាព ហើយនាធាផ្គត់ផ្គង់សំភារៈចាំបាច់ដូចជា ថ្នាំពេទ្យ បរិក្ខារពេទ្យ ឈាម និង សំភារៈដទៃទៀតដល់ជនរងគ្រោះដោយសារគ្រោះមហន្តរាយ ។

-ការងារផ្តល់ជំនួយ និងរក្សាសុខមាលភាព : ផ្តល់ជំនួយដល់ប្រជាពលរដ្ឋដែលរងគ្រោះ រៀបចំពង្រឹងសហគមន៍ដើម្បីជួយលើកស្ទួយជីវភាពរបស់សមាជិកនៃសហគមន៍នេះ ។

**៣.ក្រុម ការពារសន្តិសុខ និងទំនាក់ទំនងការងារ :**

-ការងារសន្តិសុខ : ត្រូវមានការចូលរួមពីកងកំលាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ និងអាវុធហត្ថជាតិ ដើម្បីសហការការពារសន្តិសុខ របៀបរៀបរយ អាយុជីវិតប្រជាពលរដ្ឋ និងទ្រព្យសម្បត្តិនៅតំបន់ដែលកើតមានគ្រោះមហន្តរាយ ។

-ការងារទំនាក់ទំនង : ត្រូវប្រើប្រាស់គ្រប់មធ្យោបាយដែលមាន និងជំនួយសង្គ្រោះពីភ្នាក់ងារនានាដើម្បីផ្តល់ដល់ផ្នែកគ្រប់គ្រងកិច្ចប្រតិបត្តិការគ្រោះមហន្តរាយ ។

មាត្រា ៧ : គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ក្រុង មានសមាសភាពដូចខាងក្រោម :

-អភិបាលខេត្ត ក្រុង ជាប្រធាន

-អភិបាលរងទីមួយ ខេត្ត ក្រុង ជាអនុប្រធាន

-ចៅក្រសួងដទៃទៀត ជាសមាជិក

មាត្រា ៨ : គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ក្រុងមានតួនាទី និងភារកិច្ចដូចខាងក្រោម :

១-អនុវត្តគោលការណ៍ដែលទាក់ទងទៅនឹងការគ្រប់គ្រងគ្រោះមហន្តរាយ ។

២-ផ្តល់យោបល់ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ស្តីពីការបង្ការគ្រោះមហន្តរាយ ការត្រៀមលក្ខណៈទប់ទល់គ្រោះមហន្តរាយ ការប្រតិបត្តិការនៅពេលមានគ្រោះមហន្តរាយ ការជំរុញការ...ស្តារស្ថានភាពឡើងវិញ ដោយរាជរដ្ឋាភិបាល កាកបាទក្រហមកម្ពុជា ព្រមទាំងការ ... អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ នានា ។

...គ្រប់គ្រងគ្រោះមហន្តរាយដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក

៤-ស្នើមូលនិធិ និងមធ្យោបាយសំភារៈពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

៥-ធ្វើរបាយការណ៍ស្តីពីការខូចខាតដោយគ្រោះមហន្តរាយជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

៦-រៀបចំកម្មវិធីបណ្តុះបណ្តាល ដើម្បីបង្កើនបច្ចេកទេសជំនាញដល់សមាជិក ។

៧-ណែនាំពីរបៀបគ្រប់គ្រងដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ ស្រុក ខ័ណ្ឌ ។

មាត្រា ៩ : សមាជិកនៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត ក្រុង ត្រូវចូលរួមប្រជុំអោយបានទៀងទាត់តាមការកោះអញ្ជើញរបស់ប្រធាន ។

មាត្រា ១០ : លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត ក្រុង មានរចនាសម្ព័ន្ធគ្រប់គ្រងដូចគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រោមការដឹកនាំរបស់លេខាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត ក្រុង ហើយស្ថិតនៅក្រោមការរៀបចំរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ថ្នាក់ខេត្ត ក្រុង ។ លេខាធិការដ្ឋាននេះអនុវត្តការងារគ្រប់គ្រងគ្រោះមហន្តរាយរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ថ្នាក់ខេត្ត ក្រុង ។

**មាត្រា ១១ :** គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ខ័ណ្ឌ មានសមាសភាពដូចខាងក្រោម :

-អភិបាលស្រុក ខ័ណ្ឌ ជាប្រធាន

-អភិបាលរងទីមួយ ស្រុក ខ័ណ្ឌ ជាអនុប្រធាន

-ប្រធានការិយាល័យដទៃទៀត សមាជិក

**មាត្រា ១២ :** គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដូចខាងក្រោម :

១-អនុវត្តគោលការណ៍ដែលទាក់ទងទៅនឹងការគ្រប់គ្រងគ្រោះមហន្តរាយ ។

២-ផ្តល់យោបល់ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ថ្នាក់ខេត្ត ក្រុង ពីស្ថានភាពគ្រោះមហន្តរាយ ។

៣-រៀបចំកម្មវិធីបណ្តុះបណ្តាលប្រជាពលរដ្ឋ ពីការគ្រប់គ្រងគ្រោះមហន្តរាយ ។

៤-រៀបចំការអប់រំ និងផ្សព្វផ្សាយជាសាធារណៈ ពីគ្រោះថ្នាក់នៃគ្រោះមហន្តរាយ

៥-ស្នើអ្នកជំនួយការ ពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត ក្រុង ដើម្បីដឹកនាំកិច្ចប្រតិបត្តិការពេលមានគ្រោះមហន្តរាយ ដូចជា ការសង្គ្រោះ ជម្លៀស រកទីជំរក និងរកជំនួយថ្នាំពេទ្យ ។

៦-ធ្វើរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត ក្រុង ពីស្ថានភាពនៃគ្រោះមហន្តរាយ ។

**មាត្រា ១៣ :** សមាជិកនៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ស្រុក ខ័ណ្ឌ ត្រូវចូលរួមប្រជុំ អោយបានទៀងទាត់តាមការកោះអញ្ជើញរបស់ប្រធាន ។

**មាត្រា ១៤ :** លេខាធិការដ្ឋាននេះ មានរចនាសម្ព័ន្ធ និងតួនាទីដូចគណៈកម្មាធិការគ្រប់ គ្រងគ្រោះ មហន្តរាយថ្នាក់ខេត្ត ក្រុង ក្រោមការដឹកនាំរបស់លេខាធិការអចិន្ត្រៃយ៍មួយរូបដែលកំណត់ដោយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ស្រុក ខ័ណ្ឌ ។ លេខាធិការដ្ឋាននេះអនុវត្តការងារគ្រប់គ្រងគ្រោះមហន្តរាយរបស់ ស្រុក ខ័ណ្ឌ ។

**មាត្រា ១៥ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងគ្រប់គ្រងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ និងយុទ្ធជន

រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម ថាមពល និងរ៉ែ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការក្រសួងធម្មការ និងកិច្ចការសាសនា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានកិច្ចការនារី ប្រធានកាកបាទក្រហមកម្ពុជា ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

*រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៩៥*

## អនុក្រឹត្យលេខ ៣៦ អនក្រ
## ស្តីពីការផ្ទេរ និង តែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងលោក **សួន រិនឌី** ជាអភិបាលខ័ណ្ឌដូនពេញ រាជធានីភ្នំពេញជំនួសលោក **ប៉ាសុជាតិវង្ស** ដែលត្រូវផ្ទេរអោយទៅបំរើការងារថ្មីនៅទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។